# ព្រះរាជក្រម

នស/រកម/១០០៥/០៣៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម លើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រណែតធឺឡែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការជំរុញ និង ការការពារ ទៅវិញទៅមកនូវការវិនិយោគរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រណែតឺឡង់

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងការការពារទៅវិញទៅមកនូវការវិនិយោគរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រណែតឺឡង់ ដែលធ្វើនៅទីក្រុងភ្នំពេញ នាថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នស/រកម.០៥១០.០៤២

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខៈ ៤១៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០០៥

អគ្គលេខាធិការរងរដ្ឋាភិបាល

ឈាវី តាន់

# កិច្ចព្រមព្រៀង
# ស្តីពី
# ការជំរុញ និង ការការពារទៅវិញទៅមកនូវការវិនិយោគ
# រវាង
# ព្រះរាជាណាចក្រកម្ពុជា
# និង
# ព្រះរាជាណាចក្រ ណែតធើឡែន

**ព្រះរាជាណាចក្រកម្ពុជា**

និង

**ព្រះរាជាណាចក្រណែតធើឡែន**

ចាប់ពីពេលនេះតទៅហៅថា " ភាគីជាប់កិច្ចសន្យា"

ក្នុងស្មារតីពង្រឹងនូវចំណងមិត្តភាពជាប្រពៃណី និង បង្កើននូវទំនាក់ទំនងសេដ្ឋកិច្ច រវាងភាគី ទាំងពីរ ពិសេស ចំពោះកិច្ចការវិនិយោគរបស់ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាង នៅលើទឹកដី នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

ដោយទទួលស្គាល់ថា ការព្រមព្រៀងគ្នាទៅលើប្រព្រឹត្តកម្មទៅលើវិនិយោគ និងជំរុញអោយមានលំហូរចូលនៃមូលធន និង បច្ចេកវិជ្ជា នឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច នៃភាគីជាប់កិច្ចសន្យាទាំងពីរ ហើយប្រព្រឹត្តកម្មដោយយុត្តិធម៌ និង តាមសមធម៌ ចំពោះវិនិយោគ គឺជា ប្រការដែលគួរអោយចង់បាន ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចតទៅ :

## មាត្រានី ១
## និយមន័យ

ចំពោះគោលបំណងនៃកិច្ចព្រមព្រៀងនេះ :

(ក) ពាក្យ "ទិនិយោគទុន " មានន័យថា ទ្រព្យសម្បត្តិគ្រប់ប្រភេទ និង ជាពិសេស តែមិនកំរិតទាំងស្រុង ត្រឹមទ្រព្យសម្បត្តិទាំងនេះឡើយនូវៈ

(i) ចលនៈទ្រព្យនិង អចលនៈទ្រព្យ ព្រមទាំងសិទ្ធិដទៃទៀតដែលពាក់ព័ន្ធទៅនឹងទ្រព្យសម្បត្តិគ្រប់ប្រភេទ ។

(ii) សិទ្ធិជាភាគហ៊ុន ប័ណ្ណធានា និង ផលប្រយោជន៍ផ្សេងៗទៀតនៅក្នុងក្រុមហ៊ុន និង ក្នុងសម្ព័ន្ធអាជីវកម្មចំរុះ

(iii) ការទាមទារប្រាក់ ទ្រព្យសម្បត្តិផ្សេងទៀត ឬ ប្រតិបត្តិការដែលមានតំលៃសេដ្ឋកិច្ច ។

(iv) សិទ្ធិក្នុងវិស័យកម្មសិទ្ធិបញ្ញា ក្បួនខ្នាតបច្ចេកវិទ្យា កិត្តិនាមជំនួញ ឬ ស្នាដៃយល់ដឹង ។

(v) សិទ្ធិដែលបានទទួលដោយច្បាប់សាធារណៈ ឬ តាមកិច្ចសន្យា ដែលរួមទាំងសិទ្ធិធ្វើបុរេសនា សិទ្ធិរុករក សិទ្ធិធ្វើនិស្សារណកម្ម និង សិទ្ធិទទួលផលពីធនធានធម្មជាតិ ។

(ខ) ពាក្យ " ជនជាតិ " ចំពោះភាគីនីមួយៗមានៈ

(i) រូបវ័ន្តបុគ្គលដែលមានសញ្ជាតិរបស់ភាគីជាប់កិច្ចសន្យា

(ii) នីតិបុគ្គលដែលបង្កើតឡើងក្រោមច្បាប់នៃភាគីជាប់កិច្ចសន្យា

(iii) នីតិបុគ្គលដែលមិនបានបង្កើតឡើងក្រោមច្បាប់នៃភាគីជាប់កិច្ចសន្យាទេ ប៉ុន្តែស្ថិតនៅក្រោមការត្រួតពិនិត្យដោយផ្ទាល់ ឬ ប្រយោលដោយរូបវ័ន្តបុគ្គល ដូចបានកំណត់ក្នុងនិយមន័យ (i) ឬ ដោយនីតិបុគ្គលដូចបានកំណត់ក្នុងនិយមន័យ (ii)

(គ) " ទឹកដី " មានន័យថា :

- ចំពោះព្រះរាជាណាចក្រកម្ពុជា គឺទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានទាំងតំបន់សមុទ្ររាប់បញ្ចូលទាំងបាត សមុទ្រ និង ស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងព្រំដែនខាងក្រៅនៃដែនសមុទ្រហើយដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិគ្រប់គ្រងអធិបតេយ្យភាព និងការពារកិច្ចគ្រប់គ្រងតាមផ្លូវច្បាប់ ដោយអនុលោមតាមច្បាប់អន្តរជាតិ ។
- ចំពោះព្រះរាជាណាចក្រណែតធឺឡេន គឺទឹកដីនៃព្រះរាជាណាចក្រណែតធឺឡេន រួមទាំងរាល់តំបន់ទាំងឡាយដែលភ្ជាប់នឹងដែនសមុទ្រដែលជាតំបន់សេដ្ឋកិច្ចផ្តាច់មុខ ឬ ជាតំបន់ស្រទាប់ដី

ដីក្រោមសមុទ្រនៃព្រះរាជាណាចក្រហ្វែតធីឡេន ក្រោមច្បាប់របស់ហ្វែតធីឡេន និងស្របតាមច្បាប់អន្តរជាតិ ដែលព្រះរាជាណាចក្រ ហ្វែតធីឡេន មានសិទ្ធិ គ្រប់គ្រងអធិបតេយ្យភាព និងការតព្វកិច្ចគ្រប់គ្រងតាមផ្លូវច្បាប់។

## មាត្រានី ២
## ការជំរុញ ការវិនិយោគទុន

ភាគីជាប់កិច្ចសន្យានីមួយៗត្រូវជំរុញ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច តាមរយៈកិច្ចការពារជនជាតិរបស់ភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលធ្វើវិនិយោគក្នុងទឹកដីរបស់ខ្លួន ដោយអនុលោមទៅតាមក្របខ័ណ្ឌនៃច្បាប់ និង បទបញ្ញត្តិរបស់ខ្លួន។
ភាគីជាប់កិច្ចសន្យានីមួយ ៗ ត្រូវទទួលស្គាល់វិនិយោគទុន ស្របតាមសិទ្ធិដែលច្បាប់ និងបទបញ្ញត្តិបានផ្តល់ជូន។

## មាត្រានី ៣
## ប្រព្រឹត្តកម្មដោយយុត្តិធម៌ និង តាមសមធម៌ ប្រព្រឹត្តកម្មជាតិ និង ប្រព្រឹត្តកម្មសំរាប់ប្រជាជាតិទទួលការអនុគ្រោះបំផុត

១- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវធានាផ្តល់នូវប្រព្រឹត្តកម្ម ដោយយុត្តិធម៌ និងតាមសមធម៌ ចំពោះវិនិយោគទុនរបស់ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនិងមិនធ្វើអោយខូចប្រយោជន៍ដោយវិធានការណ៍ មិនសមហេតុផល ឬ រើសអើង ចំពោះប្រតិបត្តិការ ការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ការទទួលផលឬការចាត់ចែងវិនិយោគរបស់ជនជាតិទាំងនោះឡើយ។
ភាគីជាប់កិច្ចសន្យានីមួយៗ នឹងផ្តល់ដល់វិនិយោគទុននោះ នូវសន្តិសុខខាងរាងកាយ និង កិច្ចការពារយ៉ាងពេញលេញ ។

២- ជាប្រការសំខាន់ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវផ្តល់ចំពោះការវិនិយោគនេះនូវប្រព្រឹត្តកម្ម ដែលមិនអាចតិចជាងអ្វីដែលខ្លួនបានផ្តល់អោយចំពោះការវិនិយោគរបស់ជនជាតិខ្លួន ឬ ការវិនិយោគនៃជនជាតិរដ្ឋទី៣ ពោលគឺផ្តល់នូវភាពអនុគ្រោះណាមួយដែលមានលក្ខណៈប្រសើរជាង ។

៣- ប្រសិនបើភាគីជាប់កិច្ចសន្យាមួយ បានផ្តល់អោយនូវអត្ថប្រយោជន៍ពិសេស ដល់ជនជាតិនៃរដ្ឋទី ៣ ណាមួយអាស្រ័យដោយមានកិច្ចព្រមព្រៀងអោយបង្កើតនូវសហព័ន្ធគយ, សហព័ន្ធសេដ្ឋកិច្ច សហព័ន្ធរូបិយវត្ថុឬស្ថាប័នប្រហាក់ប្រហែលគ្នានោះឬលើមូលដ្ឋាននៃកិច្ចព្រមព្រៀងអន្តរកាល ដែលអាចនាំទៅដល់ការបង្កើតសហព័ន្ធ ឬស្ថាប័នទាំងនោះ ភាគីជាប់កិច្ចសន្យានោះ នឹងពុំមានកាតព្វកិច្ចផ្តល់អោយនូវអត្ថប្រយោជន៍ដូចគ្នាខាងលើនេះ ដល់ជនជាតិទាំងឡាយនៃភាគីជាប់កិច្ច សន្យាម្ខាងទៀតឡើយ ។

៤- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវគោរពរាល់កាតព្វកិច្ច ដែលនឹងចូលជាធរមានទាក់ទងដល់ វិនិយោគទុន នៃជនជាតិរបស់ភាគី ជាប់កិច្ចសន្យាម្ខាងទៀត ។

៥- ប្រសិនបើបញ្ញត្តិនៃច្បាប់របស់ភាគីជាប់កិច្ចសន្យាណាមួយ ឬ កាតព្វកិច្ចក្រោមច្បាប់អន្តរជាតិដែល ដែលមានស្រាប់នាពេលបច្ចុប្បន្ន ឬ បានបង្កើតឡើងនាពេលក្រោយ រវាងភាគីជាប់កិច្ចសន្យាដែលជាការបន្ថែមលើកិច្ចព្រមព្រៀងនេះ មានកំណត់នូវបទបញ្ញត្តិជាទូទៅ ឬជាពិសេសដែលបរិយាយអំពីការវិនិយោគរបស់ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត នូវប្រព្រឹត្តកម្មដែលមានភាពអនុគ្រោះជាងអ្វីដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងនេះ បទបញ្ញត្តិនោះនឹងមានវិសាលភាពអនុវត្តក្នុងការផ្តល់ភាពអនុគ្រោះជាងអ្វីដែលកិច្ចព្រមព្រៀងបច្ចុប្បន្នបានកំណត់ ។

## មាត្រាទី ៥

## ពន្ធ-អាករ

ចំពោះពន្ធដារ, គយ, បន្ទុកចំណាយ និង ការបន្ថយពន្ធ និង ការលើកលែងពន្ធ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវផ្តល់នូវការយល់ព្រមដល់ជនជាតិ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលបានអនុវត្តរាល់សកម្មភាពសេដ្ឋកិច្ចនៅលើទឹកដីរបស់ខ្លួន នូវប្រព្រឹត្តកម្មអនុគ្រោះមិនតិចជាងអ្វី ដែលខ្លួនបានផ្តល់ទៅអោយជនជាតិខ្លួន ឬជនជាតិនៃរដ្ឋទី៣ក្នុងកាលៈទេសៈដូចគ្នានោះ ពោល គឺផ្តល់នូវភាពអនុគ្រោះណាមួយដែលមានលក្ខណៈប្រសើរជាង ។ទោះជាយ៉ាងនេះក៏ដោយក្នុងន័យនេះ មិនត្រូវមានផលប្រយោជន៍ផ្នែកពន្ធដារពិសេសជូនទៅ

ភាគីនោះ

ក) ស្ថិតក្រោមកិច្ចព្រមព្រៀងនៃការមិនយកពន្ធត្រួតគ្នា ឬ

ខ) ដោយផ្អែកលើការចូលរួមរបស់ភាគីនោះទៅក្នុងសហព័ន្ធគយ, សហព័ន្ធសេដ្ឋកិច្ច ឬស្ថាប័នប្រហាក់ប្រហែល ឬ

គ) លើមូលដ្ឋាននៃភាពអនុគ្រោះទៅវិញទៅមកជាមួយរដ្ឋទី៣ ។

## មាត្រានី ៥
## ការផ្ទេរប្រាក់

ភាគីជាប់កិច្ចសន្យានីមួយៗត្រូវធានាផ្តល់ការអនុញ្ញាតនូវការផ្ទេរប្រាក់ដែលទាក់ទងនឹងការវិនិយោគ។ ការផ្ទេរ ត្រូវធ្វើទៅបានដោយប្រើរូបិយប័ណ្ណដែលអាចប្តូរជាសេរី មិនមានរឹងអឹង ឬ ដោយគ្មានការពន្យាពេល។ ការផ្ទេរនោះត្រូវរាប់បញ្ចូលជាពិសេសតែមិនក៏តែទាំងស្រុងត្រឹមតែៈ

ក- ប្រាក់ចំណេញ , ការប្រាក់ , ការចំណេញតាមភាគហ៊ុន និង ប្រាក់ចំណូលផ្សេង ៗ ទៀត

ខ- មូលនិធិចាំបាច់

(i) សំរាប់ទិញវត្ថុធាតុដើម ឬ សំភារៈបន្ទាប់បន្សំ ផលិតផលពាក់កណ្តាលសំរេច ឬ ផលិតផលសំរេច ឬ

(ii) ដើម្បីដាក់ជំនួសទុន សំដៅធានានិរន្តភាពនៃដំណើរការវិនិយោគ ។

គ- មូលនិធិបន្ថែមចាំបាច់សំរាប់អភិវឌ្ឍន៍ ដំណើរការវិនិយោគ។

ឃ- មូលនិធិក្នុងការទូទាត់សងវិញ នូវប្រាក់កម្ចី ។

ង- សួយសារអាករ ឬ កំរៃ

ច- ចំណូលរបស់រូបវន្តបុគ្គល

ឆ- ប្រាក់ចំណូលដែលបានមកពីការលក់ ឬ ការរំសាយវិនិយោគ

ជ- ការទូទាត់សងចំពោះការខាតបង់ ដូចមានចែងក្នុងមាត្រា ៧ ។

## មាត្រាទី ៦
## ការដកហូត

គ្មានភាគីជាប់កិច្ចសន្យាណាមួយ អាចមានវិធានការ ដើម្បីធ្វើការដកហូតការវិនិយោគរបស់ជនជាតិនៃភាគីជាប់កិច្ចសន្យាមួយទៀត ដោយផ្ទាល់ ឬ ដោយប្រយោល លើកលែងតែបានបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

ក-រាល់វិធានការណ៍ទាំងអស់ត្រូវបានធ្វើឡើង ដើម្បីជាផលប្រយោជន៍សាធារណៈ ហើយស្ថិតនៅក្រោមនីតិវិធីនៃច្បាប់ ។

ខ-វិធានការណ៍ទាំងអស់ត្រូវធ្វើដោយគ្មានការរើសអើង ឬ មិនផ្ទុយទៅនឹងវិធានការណ៍ដែលភាគីជាប់កិច្ចសន្យាប្រកាន់យកនោះឡើយ ។

គ-រាល់វិធានការណ៍ទាំងអស់ដែលប្រកាន់យកត្រូវភ្ជាប់ជាមួយនូវសំណង ។ សំណងនោះត្រូវគិតលើតំលៃពិតនៃការវិនិយោគដែលរងផលប៉ះពាល់ហើយត្រូវបូកបញ្ចូលផងដែរនូវការប្រាក់តាមអត្រាជាធរមានរហូតដល់ថ្ងៃទូទាត់ហើយការទូទាត់សោតត្រូវបង្កអោយមានភាពងាយស្រួលក្នុងការផ្ទេរបានជារូបិយវត្ថុទៅប្រទេសរបស់សាម៉ីជនអ្នកតវ៉ា និង ជារូបិយវត្ថុនៃប្រទេសដែលអ្នកតវ៉ាជាជនជាតិរបស់ប្រទេសនោះ ឬ ជារូបិយវត្ថុអាចប្តូរបានដោយសេរីណាមួយ ដែលយល់ព្រមពីអ្នកតវ៉ា និងដោយគ្មានការពន្យាពេល ។

## មាត្រាទី ៧
## សំណងចំពោះការខាតបង់

១- រាល់ជនជាតិទាំងអស់ នៃភាគីជាប់កិច្ចសន្យាណាមួយ ដែលទទួលរងនូវការខាតបង់ដោយសារតែសង្គ្រាមឬ ជំលោះអាវុធផ្សេងៗ បដិវត្តន៍ ការប្រកាសប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ការបះបោរ កុប្បកម្ម ឬ ជំលោះចលាចល នៅក្នុងទឹកដី នៃភាគីជាប់កិច្ចសន្យាម្ខាងទៀតដែលខ្លួនធ្វើវិនិយោគ នឹងត្រូវបានទទួលពីភាគីជាប់កិច្ចសន្យានេះនូវប្រព្រឹត្តកម្មជា ការសងវិញ, សំណង, ការទូទាត់សង ឬ ដំណោះស្រាយផ្សេងទៀត ដែលមានលក្ខណៈ អនុគ្រោះមិនតិចជាងអ្វីដែលភាគីជាប់កិច្ចសន្យានេះបានផ្តល់អោយជនជាតិខ្លួនឬជនជាតិនៃរដ្ឋទី ៣ ពោល គឺ ផ្តល់នូវភាពអនុគ្រោះណាមួយដែលមានលក្ខណៈប្រសើរជាង ។

## មាត្រានី ៨

## ឧបាទេសកម្ម

ប្រសិនបើការវិនិយោគ ដែលធ្វើឡើងដោយជនជាតិ នៃភាគីជាប់កិច្ចសន្យាមួយ ត្រូវបានធានាទល់នឹងហានីភ័យមិនមែនពាណិជ្ជកម្ម ឬម្យ៉ាងទៀតនាំបង្កើតអោយមានសំណងនៃការខូចខាតចំពោះការវិនិយោគបែបនេះក្រោមប្រព័ន្ធមួយដែលបានបង្កើតឡើងដោយច្បាប់ បទបញ្ញត្តិ ឬ កិច្ចសន្យារបស់រដ្ឋាភិបាល សិទ្ធិឧបាទេសកម្មនៃអ្នកធានា ឬ អ្នកធានាបន្ត ឬ ភ្នាក់ងារដែលបានតែងតាំងដោយភាគីជាប់កិច្ចសន្យាម្ខាងលើសិទ្ធិរបស់ជនជាតិខាងលើនេះ ដែលអនុលោមទៅតាមល័ក្ខខ័ណ្ឌនៃការធានាឬ ក្រោមរូបភាពសំណងណាមួយនោះ ត្រូវតែបានទទួលស្គាល់ដោយភាគីជាប់កិច្ចសន្យាម្ខាងទៀត។

## មាត្រានី ៩

## ដំណោះស្រាយវិវាទរវាងជនជាតិ និង ភាគីជាប់កិច្ចសន្យា

១- វិវាទដែលកើតឡើងរវាងជនជាតិនៃភាគីជាប់កិច្ចសន្យាមួយ ជាមួយភាគីជាប់កិច្ចសន្យាម្ខាងទៀតដែលទាក់ទងដល់ផលវិនិយោគរបស់ភាគីទី១ ហើយដែលមិនបានដោះស្រាយដោយមិត្តភាពនោះ ក្រោយរយៈពេល ៣ខែ គិតពីថ្ងៃដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរនៃការតវ៉ា ត្រូវបញ្ជូនបណ្តឹងទៅមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ ដើម្បីដោះ ស្រាយ ប្រសិនបើភាគីជាជនជាតិនោះមានបំណង ។

២- ក្នុងករណីវិវាទត្រូវបានបញ្ជូនទៅមជ្ឈត្តវិនិច្ឆ័យអន្តរជាតិ ជនជាតិនោះ អាចជ្រើសរើសលើកវិវាទនោះទៅ :

ក-មជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ ដើម្បីដោះស្រាយតាមការស្រុះស្រួល ឬ តាមរយៈមជ្ឈត្តវិនិច្ឆ័យ (ដែលអាចអនុវត្តន៍បានសំដៅទៅលើបញ្ញត្តិនៃ អនុសញ្ញាស្តីពីដំណោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និងជនជាតិនៃរដ្ឋនានា ដែលបានបើកចំហរការចុះហត្ថលេខានៅទីក្រុងវ៉ាស៊ីនតោនឌីស៊ីកាលពីថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៦៥ និងវិធានការណ៍បន្ថែមតាមការផ្សះផ្សារបែបរដ្ឋបាល ឬតាមរយៈអាជ្ញាកណ្តាល និង វិធីស្វែងយល់ដទៃទៀត ) ឬ

ខ-តុលាការអាជ្ញាកណ្តាលនៃសភាពាណិជ្ជកម្មអន្តរជាតិ ឬ

គ-អាជ្ញាកណ្តាលអន្តរជាតិ ឬ តុលាការអាជ្ញាកណ្តាល អាត់-ហុក ដែលបានបង្កើតឡើងដោយកិច្ចព្រមព្រៀងពិសេស ឬ បង្កើតឡើងក្រោមច្បាប់មជ្ឈត្តវិនិច្ឆ័យនៃគណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ។

៣- នីតិបុគ្គលដែលជាជនជាតិនៃភាគីជាប់កិច្ចសន្យាមួយ ហើយដែលមុនពេលមានវិវាទកើតឡើង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនជាតិ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដោយយោងទៅនឹងមាត្រា២៥ (២) (ខ) នៃអនុសញ្ញា ត្រូវបានចាត់ទុកថាជាជនជាតិ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

៤- ការសំរេចក្តី របស់អាជ្ញាកណ្តាលគឺជាការសំរេចចុងក្រោយ ដោយភាគីទាំងសងខាងត្រូវតែគោរពហើយត្រូវអនុវត្តតាមច្បាប់ជាតិ ។

៥- ភាគីជាប់កិច្ចសន្យានីមួយៗ យល់ព្រមនឹងដាក់ឆ្លងរាល់ករណី វិវាទផ្នែកវិនិយោគដើម្បីរកដំណោះស្រាយតាមការជ្រើសរើសវិធានការណ៍ដែលបានកំណត់ក្នុងវាក្យខ័ណ្ឌខាងដើម ។

## មាត្រានី ១០
## វិសាលភាពគ្របដណ្តប់ នៃ កិច្ចព្រមព្រៀង

បណ្តាមាត្រានៃកិច្ចព្រមព្រៀងនេះ មានប្រសិទ្ធភាពអនុវត្តដោយគិតចាប់ពីថ្ងៃចូលជាធរមានតទៅ ហើយត្រូវអនុវត្តផងដែរចំពោះការវិនិយោគទាំងឡាយដែលបានធ្វើមុនថ្ងៃចូលជាធរមាននេះ ប៉ុន្តែមិនគ្របដណ្តប់ចំពោះរាល់វិវាទ ការតវ៉ា ឬទំនាស់ផ្សេងៗទៀត ដែលបានកើតឡើងមុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនោះឡើយ ។

## មាត្រានី ១១
## ជំនួបពិគ្រោះយោបល់

ភាគីជាប់កិច្ចសន្យានីមួយៗ អាចស្នើទៅភាគីម្ខាងទៀតអោយមានជំនួបពីគ្រោះយោបល់លើរាល់បញ្ហាដែលទាក់ទង នឹងការបកស្រាយ ឬការអនុវត្តនីកិច្ចព្រមព្រៀង ។ ភាគីម្ខាងទៀតត្រូវផ្តល់ការយកចិត្តទុកដាក់ចំពោះសំណើនេះហើយត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ចំពោះជំនួបពិគ្រោះនេះ ។

## មាត្រានី ១២
## ការដោះស្រាយវិវាទ រវាងភាគីជាប់កិច្ចសន្យា

១- វិវាទណាមួយ រវាងភាគីជាប់កិច្ចសន្យាដែលទាក់ទងដល់ការបកស្រាយ ឬ ការអនុវត្តន៍កិច្ចព្រមព្រៀងនេះហើយដែលមិនអាចដោះស្រាយបាន នៅក្នុងពេលវេលាសមស្របតាមការចរចារផ្លូវទូតទេ លើកលែងតែភាគីទាំងពីរបានឯកភាពគ្នាដោះស្រាយតាមផ្លូវណាផ្សេងនោះ វិវាទនោះត្រូវស្នើឡើង ដោយភាគីជាប់កិច្ចសន្យាណាមួយ ទៅតុលាការអាជ្ញាកណ្តាល ដែលមានសមាជិក៣ រូប ។ ភាគីជាប់កិច្ចសន្យានីមួយ ១ ត្រូវតែងតាំងមជ្ឈត្តកររបស់ខ្លួនមួយរូប និងមជ្ឈត្តករទាំងពីររូបនោះ នឹងតែងតាំងមជ្ឈត្តករទី៣ធ្វើជាប្រធានដែលប្រធាននោះមិនអាចជាជនជាតិនៃភាគីណាមួយឡើយ ។

២- ប្រសិនបើភាគីណាមួយ មិនបានធ្វើការតែងតាំងមជ្ឈត្តកររបស់ខ្លួន ហើយក្នុងរយៈពេល ០២ខែ ភាគីនោះពុំបានធ្វើការតែងតាំង ក្រោយពីមានការអញ្ជើញសុំអោយធ្វើការតែងតាំងពីសំណាក់ភាគីម្ខាងទៀត ភាគីទី២អាចស្នើប្រធានតុលាការអន្តរជាតិធ្វើការតែងតាំងជាចាំបាច់ ។

៣- ក្នុងរយៈពេល ០២ ខែ បន្ទាប់ពីការតែងតាំង បើប្រសិនមជ្ឈត្តករទាំងពីររូប មិនមានការឯកភាពគ្នាក្នុងការជ្រើសរើសមជ្ឈត្តករទី៣ ទេនោះ ភាគីជាប់កិច្ចសន្យានីមួយ១ អាចស្នើប្រធាននៃតុលាការអន្តរជាតិធ្វើការតែងតាំងជាចាំបាច់ ។

៤- ប្រសិនបើក្នុងករណីដូចមានចែងក្នុងវាក្យខ័ណ្ឌ(២)និង (៣) នៃមាត្រានេះ ហើយប្រធានតុលាការអន្តរជាតិនោះ មិនអាចបំពេញតួនាទីនេះបាន ដោយប្រការណាមួយ ឬ ក៏ជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ អនុប្រធានតុលាការនឹងត្រូវបានស្នើធ្វើការតែងតាំងជាចាំបាច់នេះ ។ ប្រសិនបើអនុប្រធានមិនអាចបំពេញតួនាទីខាងលើនេះបានទៀតឬ ក៏ជាជនជាតិ នៃភាគីជាប់កិច្ចសន្យាណាមួយ សមាជិកតុលាការអន្តរជាតិដែលមានឋានៈខ្ពស់ជាងគេ ហើយដែលមិនមែនជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ នឹង ត្រូវបានស្នើអោយជួយធ្វើការតែងតាំងជាចាំបាច់នេះ ។

៥- តុលាការអាជ្ញាកណ្តាលធ្វើការសំរេចក្តីដោយឈរលើមូលដ្ឋាននៃការគោរពច្បាប់។ មុននឹងតុលាការធ្វើការសំរេចក្តី តុលាការអាចក្នុងដំណើរការរបស់ខ្លួន ស្នើភាគីទាំងពីរដោះស្រាយវិវាទជាមួយគ្នាជាមិត្តភាព។ រាល់បញ្ញត្តិខាងដើម នឹងមិនបង្អាក់ការវិវាទដល់ដំណោះស្រាយវិវាទទេ បើភាគីទាំងពីរមានការឯកភាពយ៉ាងណានោះ ។

៦- ល្គឹកណា ភាគីទាំងពីរ ពុំមានការសំរេចផ្សេងទេនោះ តុលាការនឹងកំណត់នូវនីតិវិធីដំណើការរបស់ខ្លួន ។

៧- តុលាការត្រូវធ្វើការសំរេចដោយការបោះឆ្នោតតាមមតិភាគច្រើន ។ការសំរេចក្តីរបស់តុលាការ គឺជាការសំរេចចុងក្រោយ ហើយភាគីទាំងពីរត្រូវតែទទួលអនុវត្ត ។

## មាត្រានី ១៣
## វិសាលភាព ចំពោះ ទឹកដី

ចំពោះព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដូចដែលមានក្នុងនិយមន័យនៃមាត្រា ១ ។
ចំពោះព្រះរាជាណាចក្រ ណែតធឺឡែន កិច្ចព្រមព្រៀងនេះត្រូវអនុវត្តលើចំណែកនៃព្រះរាជាណាចក្រ ក្នុងទ្វីបអឺរុប លើរដ្ឋ ណែតធឺឡែន អង់ទី និង លើ អារុបា ( the part of the Kingdom in Europe, to the Netherlands Antilles and Aruba ) ល្គឹកណាការជូនដំណឹងដែលមានចែងក្នុងមាត្រា ១៤ វាក្យខ័ណ្ឌ (១) មិនមានការកំណត់ផ្សេងទេនោះ ។

## មាត្រានី ១៤
## ការចូលជាធរមាន រយៈពេល និង ការបញ្ចប់

១- កិច្ចព្រមព្រៀងនេះនឹងចូលជាធរមានក្នុងថ្ងៃទីមួយ នៃ ខែទី ២ គិតរាប់ពីថ្ងៃដែលភាគីជាប់កិច្ចសន្យាបានធ្វើការជូនដំណឹងទៅវិញទៅមកជាលាយលក្ខណ៍អក្សរថា ការបំពេញនីតិវិធីតាមរដ្ឋធម្មនុញ្ញកំណត់របស់ខ្លួនសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះបានប្រព្រឹត្តទៅរួចរាល់ហើយ ។ កិច្ចព្រមព្រៀងមានសុពលភាពអនុវត្តរយៈពេល ដប់ប្រាំឆ្នាំ ។

២- លើកលែងតែមានការជូនដំណឹងស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ដោយភាគីជាប់កិច្ចសន្យាណាមួយយ៉ាងតិច ៦ខែ មុនពេលផុតសុពលភាព កិច្ចព្រមព្រៀងនេះនឹងបន្តមានតំលៃសំរាប់រយៈពេល ១៥ ឆ្នាំទៀត ។តាមរយៈនេះ ភាគីជាប់កិច្ចសន្យានីមួយៗ រក្សាសិទ្ធិដើម្បីបញ្ចប់កិច្ចព្រមព្រៀង ដោយជូនដំណឹងយ៉ាងតិច ០៦ខែ មុនពេលផុតសុពលភាព ។

៣- ពាក់ព័ន្ធដល់ការវិនិយោគ ដែលបានធ្វើមុនថ្ងៃបញ្ចប់កិច្ចព្រមព្រៀង មាត្រាទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ត្រូវបន្តមានសុពលភាពសំរាប់រយៈពេលដប់ប្រាំឆ្នាំទៀត បន្ទាប់ពីថ្ងៃបញ្ចប់កិច្ចព្រមព្រៀង ។

៤- អនុលោមទៅតាមរយៈពេលដូចដែលបានកំណត់ក្នុងវាក្យខ័ណ្ឌ (២) នៃមាត្រានេះ ព្រះរាជាណាចក្រណែតធីឡែន មានសិទ្ធិក្នុងការបញ្ចប់កិច្ចព្រមព្រៀងនេះ ដាច់ឡែកពីគ្នាទាក់ទងទៅនឹងចំណែកណាមួយនៃព្រះរាជាណាចក្រណែតធីឡែន ។

ដើម្បីជាសាក្សីនៃកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់ដែលរដ្ឋាភិបាលរៀងខ្លួនបានប្រគល់អំណាចត្រឹមត្រូវ មានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើឡើងចំនួន ២ ច្បាប់ដើម នៅ ភ្នំពេញ ថ្ងៃទី ២៣.វិ.ឆ.២០០៣
ជាភាសា ខ្មែរ ភាសាណែតធីឡែន និង ភាសាអង់គ្លេស ។ អត្ថបទទាំងអស់មានតំលៃគតិយុត្តិដូចគ្នា ។
ក្នុងករណីមានការបកស្រាយផ្សេងគ្នានោះ ភាសាអង់គ្លេសនឹងត្រូវបានយកមកធ្វើជាសំអាង ។

| តំណាងព្រះរាជាណាចក្រកម្ពុជា | តំណាងព្រះរាជាណាចក្រណែតធីឡែន |
| --- | --- |
| គាត ឈន់ | ហ្សេរា ចេ អេច ស៊ី គ្រេម៉ែរ |
| ទេសរដ្ឋមន្ត្រី | ឯកអគ្គរាជទូត |
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | នៃព្រះរាជាណាចក្រណែតធីឡែន |